# របៀបអនុវត្តមុខងារ

## “ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះនៅក្នុងសហគមន៍”

បាត់ដំបង ថ្ងៃទី២១-២២ ខែកញ្ញា ឆ្នាំ២០១៥

---

## តើកុមារដែលត្រូវការថែទាំនៅក្នុងមណ្ឌល និងថែទាំជំនួសនៅក្នុងសហគមន៍ ស្ថិតក្នុងស្ថានភាពប្រឈមគ្រោះថ្នាក់ដូចម្ដេចខ្លះ?



...?

❶កុមារដែលគ្មានឪពុកម្ដាយ ឬអាណាព្យាបាលនៅជាមួយ

❷កុមារបែកចេញពីគ្រួសារ ឬស្ថានភាពគំរាមកំហែងដែលអាចបណ្ដាលឲ្យកុមារបែកចេញពីគ្រួសារតាមរយៈ ការបោះបង់កុមារចោល ការជាប់ពន្ធនាគារ ការជួញដូរ ឬចំណាកស្រុក

❸កុមារទទួលរងការប្រព្រឹត្តអំពើហិង្សា ឬការគម្រាម បង្កអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានលើរាងកាយ ឬផ្លូវភេទ ឬការកេងប្រវ័ញ្ចគ្រប់រូបភាពដូចជាការលក់ ឬជួលកុមារជាដើម

❹កុមារដែលឪពុកម្ដាយ ឬអាណាព្យាបាលរបស់ខ្លួនពុំមានលទ្ធភាពបំពេញភាតព្វកិច្ចបីបាច់ថែរក្សាដោយសារការខ្វះខាតតម្រូវការចាំបាច់ និងសេវាមូលដ្ឋាន ទីជម្រក ចំណីអាហារ សម្លៀកបំពាក់ ការអប់រំ និងការថែទាំសុខភាព

❺កុមារ ឬអ្នកថែទាំកុមារមានជំងឺរ៉ាំរ៉ៃ ឬមានពិការភាពដែលធ្វើឲ្យកុមារមិនអាចទទួលបានការថែទាំសមស្រប

❻កុមារដែលគ្រួសារញៀនគ្រឿងស្រវឹង លេងល្បែងស៊ីសង ប្រើប្រាស់សារធាតុញៀនផ្សេងៗដែលមិនអាចផ្ដល់ការថែទាំសមស្របដល់កុមារ

❼កុមារដែលកំពុងប្រឈម ឬកំពុងមានទំនាស់នឹងច្បាប់ ។

## គំនូសបំព្រួញនៃការថែទាំជំនួសចំពោះកុមាររងគ្រោះ និងងាយរងគ្រោះ និងការធ្វើអធិការកិច្ច




I. **របៀបអនុវត្ត** “ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះនៅក្នុងសហគមន៍”

១.ប្រមូលទិន្នន័យអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាសុខុមាលភាពកុមារនៅក្នុងឃុំ សង្កាត់

២.ប្រមូលទិន្នន័យកុមាររងគ្រោះនិងងាយរងគ្រោះនៅក្នុងឃុំ សង្កាត់

៣.រៀបចំ ដាក់បញ្ចូលបញ្ហាកុមារក្នុងផែនការវិនិយោគ និងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

៤.សម្រាប់កុមារដែលស្ថិតក្នុងស្ថានភាពប្រឈមគ្រោះថ្នាក់ក្នុងគ្រួសារ ៖

- ចុះជួបផ្ទាល់ជាមួយកុមារ និង/ឬគ្រួសារ ដើម្បីប៉ាន់ប្រមាណភាពខ្លាំង/ខ្សោយ និងតម្រូវការ ១៣០១.pdf និង ១៣០២.pdf
- ធ្វើផែនការសេវាគ្រួសារ និងស្វែងរកសេវាចាំបាច់នានា ដើម្បីរក្សាកុមារឱ្យរស់ជុំគ្រួសារ តាមដានដំណើរការវិវឌ្ឍរបស់ពួកគេ ១៣០៣.pdf
- សម្រេចបិទករណី ឬទុកដាក់កុមារជាបណ្តោះអាសន្ន តាមការថែទាំជំនួស ១៣០៤.pdf

៥.សម្រាប់កុមារដែលត្រូវបានគេបោះបង់ចោល ត្រូវរៀបចំទុកដាក់ជាបណ្តោះអាសន្ន នៅកន្លែងមួយមានសុវត្ថិភាពតាមរយៈ ៖

- ការថែទាំជាមួយសាច់ញាតិកុមារក្នុងឃុំសង្កាត់
- ទំនាក់ទំនងជាមួយក្រុមប្រឹក្សាក្រុងស្រុក ដើម្បីទុកដាក់កុមារ៖
  - ជាមួយសាច់ញាតិឆ្លងឃុំសង្កាត់
  - តាមការថែទាំជាមួយគ្រួសារធម៌
  - តាមការថែទាំជាមួយព្រះសង្ឃ កន្លែងសាសនានានា និងការថែទាំជាក្រុមក្នុងសហគមន៍
  - តាមមណ្ឌល (ជាជម្រើសចុងក្រោយ)

៦.បំពេញ រក្សា និងចម្លងជូនអាជ្ញាធរពាក់ព័ន្ធនូវទម្រង់ពាក់ព័ន្ធនានា តាមដំណាក់កាលនៃករណីកុមារម្នាក់ៗ

៧.សហការ និងសម្របសម្រួលជាមួយរដ្ឋបាលក្រុងស្រុក វត្តអារាម ទីកន្លែងសាសនានានា និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីដោះស្រាយករណីកុមារ

៨.ធ្វើសេចក្តីសម្រេច និងឯកភាពលើទម្រង់ពាក់ព័ន្ធនានា ដែលមានចែងនៅក្នុងសេចក្តីណែនាំលេខ ០០២ ស.អ.យ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣ ស្តីពីទម្រង់បែបបទ និង គំរូលិខិតបទដ្ឋានសម្រាប់អនុវត្តប្រកាសលេខ ២២៨០ ស.អ.យ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ ២០១១ស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ

៩.ធ្វើរបាយការណ៍ពីលទ្ធផលការអនុវត្តមុខងារប្រចាំខែ ត្រីមាស និងឆ្នាំជូនក្រុមប្រឹក្សាក្រុងស្រុក និងផ្ញើជូនក្រសួង ស.អ.យ តាមរយៈការិយាល័យ ស.អ.យ ក្រុង ស្រុក